**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ពុធ ១២ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០២២*

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពីជំនួបសម្ដែងការគួរសមរវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រុមបេសកកម្ម Article IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ

នារសៀលថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០២២, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលការចូលជួបពិភាក្សាការងារជាមួយក្រុមបេសកកម្ម Article IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលដឹកនាំដោយលោក **Alasdair Scott** ប្រធានក្រុមបេសកកម្ម និងមានការចូលរួមដោយលោក **Yasuhisa Ojima** តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំនៅកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃបេសកកម្ម Article IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ នាពេលនេះ ដែលនឹងមកពិភាក្សា និងផ្លាស់ប្ដូរយោបល់គ្នាអំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ខណៈដែលកម្ពុជាកំពុងរៀបចំសេចក្ដីព្រាងច្បាប់ថវិកាសម្រាប់ឆ្នាំ ២០២៣ និងក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាកាន់តែខ្លាំង នៃសេដ្ឋកិច្ចសកលលោក ដែលបង្កឡើងដោយភាពមិនអំណោយផលនៃកត្តាភូមិសាស្ត្រនយោបាយ និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលបាន និងកំពុងបង្កផលប៉ះពាល់ដោយផ្ទាល់ និងប្រយោល ។

លោក **Alasdair Scott** ប្រធានក្រុមបេសកកម្ម ក៏បានលើកឡើងពីភាពមិនប្រាកដប្រជា និងហានិភ័យកាន់តែខ្ពស់នៃសេដ្ឋកិច្ចសកល និងបានបង្ហាញពីការព្រួយបារម្ភមួយចំនួនមកលើទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៣ ដែលបណ្ដាលមកពីបញ្ហាប្រឈម និងហានិភ័យចម្បងៗ រួមមាន÷ ការបន្តកើនឡើងនូវសម្ពាធអតិផរណា, ការរឹតបន្តឹងលឿនជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុ, និងការថមថយសេដ្ឋកិច្ចរបស់ប្រទេសចិន ដែលជាបច្ច័យអវិជ្ជមានលើសកម្មភាពសេដ្ឋកិច្ចសកល ជាពិសេស ប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗ របស់កម្ពុជា ។ លោក **Alasdair Scott** ក៏បានលើកឡើងពីតម្រូវការនៃការចែករំលែកទិន្នន័យ សម្រាប់ជាធាតុចូលក្នុងការគណនាការផ្លាស់ប្ដូរឆ្នាំគោលថ្មីសម្រាប់គណនេយ្យជាតិ និងពង្រឹងគុណភាពប្រព័ន្ធស្ថិតិ ។ បន្ថែមពីនេះ បន្ទាប់ពី IMF បានធ្វើការពិនិត្យរួចមក (peer

review), ការគណនាផ.ស.ស ដោយប្រើឆ្នាំគោលថ្មី ដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិនេះ ជារួមគឺអាចទទួលយកបាន ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានលើកឡើងពីសារៈសំខាន់នៃការចែករំលែកទិន្នន័យ សម្រាប់ការវិភាគ និងបានបញ្ជាក់ពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការរៀបចំបង្កើតប្រព័ន្ធរួមមួយសម្រាប់ផ្លាស់ប្តូរទិន្នន័យពន្ធ និងស្ថិតិជាតិ និងបានសម្តែងនូវការអរគុណចំពោះ IMF សម្រាប់ការជួយពិនិត្យ និងផ្តល់យោបល់លើកិច្ចការកែសម្រួលគណនីជាតិថ្មី ការកសាងសមត្ថភាពមន្ត្រីក្នុងការវិភាគ និងព្យាករសេដ្ឋកិច្ចលើមូលដ្ឋានថ្មីសម្រាប់កម្ពុជា ផងដែរ ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ដល់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានបន្តផ្តល់ជាជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលដល់ស្ថាប័ននានា ជាពិសេស មន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំង ការវាយតម្លៃលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការផ្តល់អនុសាសន៍ល្អៗសម្រាប់ការរៀបចំគោលនយោបាយនានា កន្លងមក និងបានជូនពរក្រុមការងារឱ្យទទួលបានជោគជ័យ និងផ្លែផ្កា សម្រាប់ការបំពេញបេសកកម្មការងារក្នុងឆ្នាំ ២០២២ នេះ ។